MRLG
MEKONG REGION
LAND GOVERNANCE

DISCUSSION NOTE

# ការពិនិត្យឡើងវិញ មតិយោបល់ និងអនុសាសន៍លើ សេចក្តីព្រាងក្រមបរិស្ថាននិងធនធានធម្មជាតិ (កំណែទី ១១)

ខែមីនា ២០១៩

*ដោយ George Cooper*

ក្រសួងបរិស្ថាននៃព្រះរាជាណាចក្រកម្ពុជាបានចាប់ផ្តើមរៀបចំសេចក្តីព្រាងក្រមបរិស្ថាននិងធនធានធម្មជាតិ (ENR Code) ក្នុងឆ្នាំ ២០១៥។ បច្ចុប្បន្នក្រមនេះបានឈានដល់សេចក្តីព្រាងទី ១១.១ សម្រាប់ផ្នែកមួយចំនួន។ គេរំពឹងថារាជរដ្ឋាភិបាលនឹងពិនិត្យសម្រេចជាស្ថាពរព្រមទាំងអនុម័តលើលិខិតបទដ្ឋានគតិយុត្តិថ្មីនេះក្នុងឆ្នាំ២០១៩។ប៉ុន្តែបើទោះជាដូច្នេះក្តីដំណើរការនេះនៅមិនទាន់មានភាពច្បាស់លាស់នៅឡើយ។ ប្រសិនបើត្រូវបានអនុម័ត ក្រមបរិស្ថាននិងធនធានធម្មជាតិនេះនឹងក្លាយជាច្បាប់ដ៏វែងបំផុតមួយរបស់កម្ពុជាដែលទម្លាយនូវមូលដ្ឋានថ្មីមួយនៅក្នុងវិស័យការងារជាច្រើនផ្សេងៗគ្នាព្រមទាំង នឹងផ្តល់នូវកិច្ចការពារបរិស្ថានការបើកចំហរ និងគណនេយ្យភាពកាន់តែខ្ពស់ជាងមុនបើធៀបទៅនឹងច្បាប់នានារបស់កម្ពុជាដែលកំពុងស្ថិតនៅជាធរមាននាពេលបច្ចុប្បន្ន។

MRLG ជាមួយនឹងដៃគូរបស់ខ្លួននៅក្នុងប្រទេសកម្ពុជា រួមមានជាអាទិ៍ អង្គការ Wildlife Conservation Society (WCS), RECOFTC, វេទិកានៃ អង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា ក្រុមសន្ទានកម្មឯករាជ្យ (IMG) និងទីប្រឹក្សាឯករាជ្យមួយចំនួន ត្រូវបានគៀងគរដើម្បីវិភាគទៅលើសេចក្តីព្រាងផ្សេងៗគ្នានៃក្រមនេះ ព្រមទាំងបានចែករំលែកអនុសាសន៍ជាមួយក្រសួងបរិស្ថានក្នុងគោលបំណងក្រសួងបរិស្ថាន ក្នុងគោលបំណងធ្វើយ៉ាងណាឱ្យមានការទទួលស្គាល់កាន់តែប្រសើរជាងមុន និងកិច្ចការពារកាន់តែខ្លាំងក្លាចំពោះសិទ្ធកាន់កាប់ដីធ្លីជាលក្ខណៈប្រពៃណី និងការគ្រប់គ្រងកាន់តែប្រសើរទៅលើដីធ្លីនិងធនធានធម្មជាតិរបស់កសិករខ្នាតតូចនៅក្នុងតំបន់ការពារនិងដីព្រៃ។ ការពិនិត្យឡើងវិញនេះមានគោលបំណង "ធ្វើការវាយតម្លៃ ជារួមចំពោះអ្វីដែលបានកែប្រែ" នៅក្នុងសេចក្តីព្រាងក្រមបរិស្ថាននិងធនធានធម្មជាតិកន្លងមក និង "ប៉ាន់ប្រមាណទៅលើទំហំនៃការកែលម្អដែលអាចទាក់ទងនឹងចំណាប់អារម្មណ៍សំខាន់ៗរបស់យើង" នៅពេលធ្វើការប្រៀបធៀបរវាងសេចក្តីព្រាងទី ១០/១១ ជាមួយសេចក្តីព្រាងមុនៗដែលជាមូលដ្ឋាននៃការផ្តល់យោបល់របស់អង្គការនានា។ការពិនិត្យឡើងវិញនេះក៏មានគោលបំណង "ធ្វើការប៉ាន់ប្រមាណថាតើអនុសាសន៍ រួមដំណាក់កាលដំបូងរបស់យើងនៅមានភាពពាក់ព័ន្ធកម្រិតណា" ផងដែរ។ គោលបំណងមួយទៀតគឺ"ដើម្បីរៀបចំអនុសាសន៍សំខាន់ៗស្តីពី សេចក្តីព្រាងលើកចុងក្រោយបំផុត (សេចក្តីព្រាងទី១០ ឬទី១១ អាស្រ័យទៅតាមសំណៅចុងក្រោយដែលមាន ដោយផ្តោតលើគន្ថីទី១ ទី៤ និងទី៩) ក្រោយពិគ្រោះយោបល់ជាមួយដៃគូ"។

ខាងក្រោមនេះគឺជាអនុសាសន៍សំខាន់ៗ៖

### 1.បន្ថែមគោលការណ៍និងបទប្បញ្ញត្តិមួយស្តីពីសន្តានុក្រម ដែលផ្តល់ការបញ្ជាក់អំពីសិទ្ធកាន់កាប់ដីធ្លីជាលក្ខណៈប្រពៃណី។

ក្នុងការបន្តអភិវឌ្ឍច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ធ្លាប់មានករណីមួយចំនួននៃការទទួលស្គាល់វត្តមាននៃច្បាប់ជាលក្ខណៈប្រពៃណីទាក់ទងនឹងបញ្ហាដីធ្លីនិងធនធានធម្មជាតិព្រមទាំងការពន្យល់ថាតើច្បាប់ជាលក្ខណៈប្រពៃណីអនុវត្តចំពោះក្រុមណាខ្លះ។ បើជាដូច្នេះក្តីបន្តិចម្តងៗ និងជារួមករណីនៃការទទួលស្គាល់និងការពន្យល់ទាំងនេះមិនសូវមានភាពស៊ីសង្វាក់គ្នាឡើយ។

ជាពិសេស ការទទួលស្គាល់និងការពន្យល់ទាំងនេះមានពាក់ព័ន្ធទៅនឹងច្បាប់ភូមិបាលឆ្នាំ២០០១ ច្បាប់ស្តីពីព្រៃឈើឆ្នាំ ២០០២ ច្បាប់ស្តី ពីតំបន់ការពារធម្មជាតិ (PAL) ឆ្នាំ ២០០៨ អនុក្រឹត្យស្តីពីនិតិវិធីចុះបញ្ជីដីធ្លីសហគមន៍ជនជាតិដើមភាគតិចឆ្នាំ ២០០៩ គោលនយោបាយស្តីពីការចុះបញ្ជីនិងសិទ្ធប្រើប្រាស់ដីធ្លីរបស់សហគមន៍ជនជាតិដើមភាគតិចក្នុងប្រទេសកម្ពុជាឆ្នាំ ២០០៩ និងក្រមរដ្ឋប្បវេណីដែលបានចូលជាធរមានក្នុងឆ្នាំ ២០១១។

---

[1]កំណត់សម្គាល់នេះពិចារណាទៅលើមតិយោបល់ពីរបាយការណ៍មួយរបស់ MRLG (ខែធ្នូ ឆ្នាំ២០១៧) ទៅលើសេចក្តីព្រាងទី៦ នៃក្រម ENR : http://mrlg.org/resources/comments-on-the-proposed-environmental-code-of-cambodia-v6-and-proposed-amendments-for-a-better-recognition-of-customary-tenure-rights-in-protected-areas/, និងរបាយការណ៍ដោយឡែករបស់ WCS, RECOFTC និង NGO Forum ទៅលើសេចក្តីព្រាងផ្សេងៗគ្នានៃក្រម ENR។

[2]សេចក្តីព្រាងក្រម ENR ដែលមានក្នុងអំឡុងពេលនៃការត្រួតពិនិត្យឡើងវិញ ដែលបានធ្វើឡើងនៅពាក់កណ្តាលឆ្នាំ២០១៨នេះ គឺជាសេចក្តីព្រាងទី១០ដែលមានលក្ខ ណៈ គ្រប់ជ្រុងជ្រោយ និងសេចក្តីព្រាងទី១១ ដែលមិនទាន់មានលក្ខណៈគ្រប់ជ្រុងជ្រោយ។ រាល់ការសំដៅយោងទាំងអស់ខាងក្រោមចំពោះសេចក្តីព្រាងក្រម ENR គឺសំដៅចំពោះសេចក្តីព្រាងទី១១ លើកលែងតែមានការបញ្ជាក់ ជាក់លាក់ដោយឡែកថាប្បញ្ញតិណាមួយសំដៅយោងចំពោះសេចក្តីព្រាងទី១០។



ការយកចិត្តទុកដាក់របស់ច្បាប់ភូមិបាលទៅលើសិទ្ធជាលក្ខណៈប្រពៃណីគឺផ្តោតលើ "សហគមន៍ជនជាតិដើមភាគតិច" ដែលជាក្រុម មនុស្សមានចំនួនតិច "ដែលសមាជិកទាំងអស់បង្ហាញនូវការឯកភាពនៃជាតិពន្ធ សង្គមវប្បធម៌ និងសេដ្ឋកិច្ច ប្រតិបត្តិរបៀបរស់នៅតាមប្រពៃណី និងដាំដុះលើដីដែលខ្លួនបានកាន់កាប់ទៅតាមវិធានបែបប្រពៃណីនៃការប្រើប្រាស់ជាសមូហភាព"។តាមធម្មតាគេតែងចាត់ទុកថាសហគមន៍ទាំង នេះគឺជាជនដំបូងដែលបានតាំងលំនៅលើតំបន់ដែលពួកគេកំពុងរស់នៅបច្ចុប្បន្ន។ មានការបង្ហាញប៉ុន្តែពុំមានចែងច្បាស់លាស់ថាប្រភេទដីដែល អាចផ្តល់ប័ណ្ណកម្មសិទ្ធជូនសហគមន៍ទាំងនេះគឺជាកម្មសិទ្ធរបស់ពួកគេរួចទៅហើយ។

ច្បាប់ស្តីពីព្រៃឈើទទួលស្គាល់សហគមន៍ជនជាតិដើមភាគតិចដែលត្រូវបានទទួលស្គាល់នៅក្នុងច្បាប់ភូមិបាល។ ក៏មានការទទួលស្គាល់ផងដែរចំពោះ "សហគមន៍មូលដ្ឋាន" ដែលមាន "លំនៅដ្ឋាននៅក្នុងឬនៅក្បែរព្រៃរបស់រដ្ឋ ដែលមានទំនៀមទំលាប់ ជំនឿសាសនា និង វប្បធម៌ប្រពៃណីដែលពឹងផ្អែកលើផលនិងអនុផលព្រៃឈើសម្រាប់ការចិញ្ចឹមជីវិតរបស់ខ្លួន"។ ចំពោះសហគមន៍មូលដ្ឋានរ ស់នៅក្នុង ឬក្បែរដែន ព្រៃបម្រុងទុកអចិន្ត្រៃយ៍ រដ្ឋត្រូវបានទទួលស្គាល់និងធានាសិទ្ធិប្រើប្រាស់ជាប្រពៃណីរបស់សហគមន៍មូលដ្ឋានដែលបម្រើឱ្យទំនៀមទំលាប់ ជំនឿ សាសនា និងការរស់នៅដូចមានចែងក្នុងមា ត្រាខាងក្រោមនេះ។

ច្បាប់ស្តីពីតំបន់ការពារធនធានធម្មជាតិ (PAL) ទទួលស្គាល់ "សហគមន៍មូលដ្ឋាននិងជនជាតិដើមភាគតិច"។ សហគមន៍មូលដ្ឋាន "សំដៅលើសហគមន៍ជនជាតិដើមភាគតិច ឬក្រុមអ្នកភូមិដែលមានលំនៅដើមនៅក្នុងភូមិមួយ ឬច្រើនដែលស្ថិតនៅក្នុង ឬក្បែរតំបន់ព្រៃឈើរបស់រដ្ឋ ដែលមានប្រពៃណីទំនៀមទំលាប់ ជំនឿ សាសនា វប្បធម៌ និងការរស់នៅពឹងអាស្រ័យជាមូលដ្ឋានលើការរកផលអនុផលព្រៃឈើ និងប្រើប្រាស់ ធនធានព្រៃឈើទាំងអស់នោះ" ។ ជនជាតិដើមភាគតិចគឺជា "ប្រជាជនជាតិដើមដែលរស់នៅនៅតាមតំបន់ភ្នំ ដោយភាគច្រើនចិញ្ចឹមជីវិតដោយការ អនុវត្តកសិកម្មវិលជុំ និងការចិញ្ចឹមជីវិតបន្ថែមដទៃទៀតដូចជា ការបរបាញ់ ការនេសាទ និងការប្រមូលផល/ អនុផលព្រៃឈើ។

គិតមកទល់នឹងបច្ចុប្បន្ន សទ្ទានុក្រមនៃគោលនយោបាយស្តីពីការចុះបញ្ជីនិងសិទ្ធប្រើប្រាស់ដីធ្លីរបស់សហគមន៍ជនជាតិដើមភាគតិច ក្នុងប្រទេសកម្ពុជាឆ្នាំ ២០០៩ រួមមានសេចក្តីពណ៌នាលម្អិតបំផុតអំពីនិយមន័យ "ជនជាតិដើមភាគតិច"។ ក្រុមជាតិពន្ធដែលរស់នៅក្នុងប្រទេសកម្ពុជាអស់រយៈពេលជាយូរណាស់មកហើយ ដែលមានភាសា វប្បធម៌ ទំនៀមទំលាប់ និងប្រពៃណីផ្ទាល់ខ្លួនខុសពីខ្មែរដែលជាក្រុមជនជាតិ ភាគច្រើននៅក្នុងប្រទេស។ សហគមន៍ជនជាតិដើមភាគតិចរួមមាន៖ ព្នង គួយ ទំពួន ចារ៉ាយ គ្រឹង ព្រៅ ការវ៉ែត ស្ទៀង ក្រោល មិល កាចក់ ព័រ ខោញ ឈ្ពង សើយ ថ្មុន ស្ទួយ រដែ ខែ រ្វង ស្នួង លឿន សំរ៉ែ និងជនជាតិដើមភាគតិចដទៃទៀត។ ជនជាតិដើមភាគតិចទាំងនេះមានរបៀបរស់នៅ បែបប្រពៃណី និងធ្វើការដាំដុះលើផ្ទៃដីរបស់ពួកគេទៅតាមវិធានប្រពៃណីនៃការប្រើប្រាស់ដីតាមបែបសមូហភាព។ ជនជាតិដើមភាគតិចមានចំនួន ១% (មួយភាគរយ) នៃចំនួនប្រជាជនសរុបព្រមទាំងបាននិងកំពុងរស់នៅប្រកបដោយភាពសុខដុមរមនាជាមួយខ្មែរអស់រយៈពេលជាយូរយារណាស់មកហើយនៅ ក្នុ ងខេត្តមួយចំនួនដូចជា៖ ខេត្តរតនគិរី មណ្ឌលគិរី ក្រចេះ ព្រះវិហារ កំពង់ធំ ស្ទឹងត្រែង ឧត្តរមានជ័យ កំពង់ចាម ពោធិ៍សាត់ កំពង់ស្ពឺ កោះកុង បាត់ដំបង ព្រះសីហនុ បន្ទាយមានជ័យ សៀមរាប និងតំបន់ដទៃទៀត។

---

[3]មាត្រា២៣។

[4]មា ត្រា ២៣ ក៏បានចែងផងដែរថា "ក្នុងពេលរងចាំការកំណត់ផ្លូវច្បាប់នូវលក្ខន្តិកៈរបស់សហគមន៍ ក្រុមដែលមានជាក់ស្តែងមកទល់បច្ចុប្បន្ននេះនឹងបន្តគ្រប់គ្រងសហគមន៍និងអចលនវត្ថុរបស់ខ្លួនតាមប្រពៃណី ហើយត្រូវអនុវត្តតាមបញ្ញត្តិនៃច្បាប់នេះ។ ពាក្យថា "ក្នុងពេល រង់ចាំការកំណត់ខាងផ្លូវច្បាប់នូវលក្ខន្តិកៈរបស់សហគមន៍" គឺជារបៀបមួយដែលមិនច្បាស់លាស់ក្នុងការនិយាយថា "មុនពេលដែលដីធ្លី របស់ពួកគេត្រូវបានផ្តល់ប័ណ្ណកម្មសិទ្ធ។

[5]មាត្រា ១១, ១៥, ៣៧ និង នៅក្នុងនិយមន័យនៅក្នុងសទ្ទានុក្រមនៃ "ដីរបស់សហគមន៍ជនជាតិដើមភាគតិច"។

[6]និយមន័យនៅក្នុងសទ្ទានុក្រមនៃពាក្យ "សហគមន៍មូលដ្ឋាន"។

[7]មាត្រា៥០។

[8]និយមន័យសទ្ទានុក្រមនៃពាក្យ តំបន់អភិរក្ស តំបន់ប្រើប្រាស់ប្រកបដោយចីរភាព តំបន់សហគមន៍មូលដ្ឋាន និងតំបន់ការពាររបស់ សហគមន៍។

[9]និយមន័យនៅក្នុងសទ្ទានុក្រមនៃពាក្យ "សហគមន៍មូលដ្ឋាន"។

[10]និយមន័យនៅក្នុងសទ្ទានុក្រមនៃពាក្យ "សហគមន៍ជនជាតិដើមភាគតិច"។

សន្ធានុក្រមនៃក្រមបរិស្ថាននិងធនធានធម្មជាតិ សេចក្តីព្រាងទី ១០ កំណត់និយមន័យ "ជនជាតិដើមភាគតិច" ក្នុងលក្ខណៈស្មើរតែដូចគ្នាទាំងស្រុងទៅនឹងច្បាប់ភូមិបាល។ សេចក្តីព្រាងទី ១០ កំណត់និយមន័យ "សហគមន៍មូលដ្ឋាន" ថាជា "ក្រុមមនុស្សទោះក្នុងទំហំណាក្តីដែលសមាជិករបស់ក្រុមនោះតាំងលំនៅនិងមានអន្តរទំនាក់ទំនងក្នុងទីតាំងទីតាំងជាក់លាក់ណាមួយពឹងផ្អែករួមគ្នាទៅលើបរិស្ថានធម្មជាតិ និង/ ឬបរិស្ថានបង្កើតដោយមនុស្ស និងមានលក្ខណៈសម្បត្តិរួមគ្នាដទៃទៀតផ្អែកលើក្រុមការងារសង្គមផលប្រយោជន៍រួមគ្នា និង/ឬ បេតិកភណ្ឌវប្បធម៌ និងប្រវិត្តសាស្រ្តរួមគ្នា"។

ក្រមរដ្ឋប្បវេណីលើកឡើងដោយចំៗអំពីវត្ថុមាននិងអំណាចតាមផ្លូវច្បាប់នៃវិធានទំនៀមទំលាប់ទាក់ទងនឹងដីធ្លីមានធនធានធម្មជាតិ។ មាត្រា ១៣១ ចែងថា "សិទ្ធប្រត្យក្សដែលត្រូវបានទទួលស្គាល់ដោយវិធានទំនៀមទំលាប់ត្រូវមានអនុភាពនៅក្រោមក្រមនេះលុះត្រា តែគ្មានភាពផ្ទុយគ្នានឹងក្រមនេះឬច្បាប់ពិសេស"។ មាត្រា ៣០៦ ចែងថា "បញ្ញត្តិនៃក្រម"។

រដ្ឋប្បវេណីត្រូវយកមកអនុវត្តចំពោះកម្មសិទ្ធ និងសិទ្ធិប្រត្យក្សផ្សេងៗរបស់សហគមន៍ជនជាតិដើមភាគតិចនិងសហគមន៍ផ្សេងៗលើកលែងតែមានបញ្ញត្តិផ្សេងនៅក្នុងច្បាប់ពិសេស ឬទំនៀមបទំលាប់ ។ មាត្រា ១០៣ ចែងថា "សិទ្ធិប្រត្យក្សសំដៅលើសិទ្ធគ្រប់គ្រងលើវត្ថុដោយចំពោះ ដែលអាចអះអាងចំពោះបុគ្គលដទៃទៀតបាន។ មាត្រា ១៣២ រៀបរាប់អំពីប្រភេទនៃ "សិទ្ធិប្រត្យក្ស"។ សិទ្ធិទាំងនេះរួមមានដូចជា៖សិទ្ធកាន់កាប់កម្មសិទ្ធ សិទ្ធប្រើប្រាស់ និងប្រាតិភោគព្រមទាំងសិទ្ធដទៃទៀត។

សេចក្តីព្រាងក្រមបរិស្ថាននិងធនធានធម្មជាតិនេះបានលើកឡើងអំពី "សិទ្ធកាន់កាប់ជាលក្ខណៈប្រពៃណី" និង "ការកាន់កាប់ដីធ្លី ជាលក្ខណៈប្រពៃណី" ប៉ុន្តែពុំមាននិយមន័យពេញលេញទាំងស្រុងនិងអំណាចតាមផ្លូវច្បាប់នៃសព្ទណាមួយសព្ទខាងលើនេះទេ។ យើងជឿជាក់ថាការសរសេរសេចក្តីព្រាងក្រម ERN គឺជាឱកាសដ៏សំខាន់មួយដើម្បីកែលម្អភាពច្បាស់លាស់និងភាពស៊ីសង្វាក់គ្នានៅក្នុង ច្បាប់ផ្លូវការជាលាយលក្ខណ៍អក្សររបស់កម្ពុជាស្តីពីវិធានតាមបែបប្រពៃណីទាក់ទង នឹងសិទ្ធិកាន់កាប់ដីធ្លីនិងធនធានធម្មជាតិ។ យើងក៏ ជឿជាក់ថាការធ្វើបែបនេះ នឹងអាចជួយបង្កើនភាពច្បាស់លាស់របស់ក្រមនេះជាទូទៅផងដែរដោយហេតុផលសេចក្តីព្រាងនាពេលនោះរួមមាន ការលើកឡើង ជាច្រើនអំពីអ្វីដែលជាលទ្ធផលសំដៅដល់សិទ្ធកាន់កាប់ដីធ្លីជាលក្ខណៈប្រពៃណីដោយពុំមានការពន្យល់អំពីសិទ្ធនេះឱ្យបានពេញលេញ។ បន្ថែមលើ នេះយើងជឿជាក់ថា រាល់កិច្ចខិតខំដើម្បីផ្តល់ភាពច្បាស់លាស់កាន់តែច្រើនថែមទៀតគប្បីពង្រឹងបន្ថែមទៀតទៅលើបទប្បញ្ញត្តិនៅក្នុងច្បាប់ជាធរមាន របស់កម្ពុជា។ ហេតុនេះយើងខ្ញុំសូមស្នើឡើងថា៖

(ក) បន្ថែមមាត្រាមួយប្រហាក់ប្រហែលទៅនឹងគន្លីទី ១ ជំពូកទី ២ "គោលការណ៍ទូទៅ"

មាត្រា ១៩ គោលការណ៍ដែលចែងថាសិទ្ធិកាន់កាប់ដីធ្លីជាលក្ខណៈប្រពៃណីមានភាពសមមូលទៅ នឹងសិទ្ធជាម្ចាស់របស់សហគមន៍ទាំងអស់និងក្រុមដទៃទៀតដែលពាក់ព័ន្ធនៅក្នុងការអនុវត្តជាលក្ខណៈប្រពៃណីនិងជាសមូហភាពចំពោះដី និងធនធានធម្មជាតិ

សិទ្ធកាន់កាប់ដីដែលសមមូលនឹងសិទ្ធជាម្ចាស់ត្រូវបានធ្វើឡើងចំពោះដីនិងធនធានធម្មជាតិដោយសហគមន៍ណាមួយឬក្រុមដទៃទៀតដែលជាប់ពាក់ព័ន្ធក្នុងការអនុវត្តជាលក្ខណៈប្រពៃណីរួមមានការគ្រប់គ្រងជាសមូហភាពទាក់ទងនឹងដី និងធនធានធម្មជាតិនោះនៅពេលដីនិងធនធានធម្មជាតិទាំងអស់នោះត្រូវបានប្រើប្រាស់ផ្តាច់មុខដោយសហគមន៍ ឬក្រុមនោះ។ នៅពេលសហគមន៍ឬក្រុម មួយមានការប្រើប្រាស់ជាលក្ខណៈប្រពៃណីរួមគ្នានិងការគ្រប់គ្រងជាសមូហភាពលើដីនិងធនធានធម្មជាតិនោះជាមួយ សហគមន៍ឬក្រុម ដទៃទៀតសិទ្ធនេះមានសមមូលទៅនឹងសិទ្ធជាម្ចាស់កម្មសិទ្ធរួម។ សិទ្ធទាំងអស់នេះរារាំងមិនឱ្យដីនិងធនធានធម្មជាតិនោះត្រូវបានប្រើប្រាស់ ដោយនរណាម្នាក់ផ្សេងទៀតដោយពុំមានមានការយល់ព្រមដោយសេរីជាមុននិងផ្អែកលើព័ត៌មាន ត្រឹមត្រូវពីសហគមន៍ ឬក្រុមរងផល ប៉ះពាល់ដែរ។ សហគមន៍ និងក្រុមដែលត្រូវបានលើកឡើងរួមមានជាអាទិ៍ដូចជា៖ សហគមន៍ជនជាតិដើមភាគតិចនិងសហគមន៍ដូចមានលើកឡើងនៅក្នុងក្រមនេះ និងក្នុងច្បាប់ដទៃទៀតទាក់នឹងសិទ្ធ កាន់កាប់ដីធ្លីជាលក្ខណៈប្រពៃណី។



(ខ) បន្ថែមបទប្បញ្ញត្តិសទ្ទានុក្រមដែលមានខ្លឹមសារដូចខាងក្រោម៖

សិទ្ធតាមបែបប្រពៃណី៖ សិទ្ធដែលទទួលបានពីកម្រងសកម្មភាពទំលាប់ឬជាលក្ខណៈប្រពៃណីរយៈពេលយូរនិងដែលបានទទួលអំណាចតាមផ្លូវច្បាប់ក្នុងអង្គភាពភូមិសាស្ត្រ ឬផ្នែកសង្គម។ សិទ្ធតាមបែបប្រពៃណីមានភាពស្របច្បាប់ផ្នែកសង្គមនៅក្នុងសហាគមន៍ឬក្រុមដទៃទៀតហើយត្រូវបានគ្រប់គ្រងនិងការពារដោយសហាគមន៍និងក្រុមនោះដោយខ្លួនឯង។ សិទ្ធទាំងអស់នេះជាទូទៅត្រូវបានអនុវត្តបានអនុវត្តជាសមូហភាព។ សិទ្ធទាំងអស់នេះពាក់ព័ន្ធទៅនឹងសហាគមន៍ ឬក្រុមទាំងឡាយណាដែលសកម្មភាពរបស់ពួកគេឆ្លើយតបចំពោះនិយមន័យខាងលើដោយមិនគិតអំពីជាតិពន្ធរបស់សហាគមន៍ឬសមាជិកក្រុមនោះឡើយ។ ដោយហេតុនេះសិទ្ធទាំងនេះអាចត្រូវ បានកាន់កាប់ដោយជាតិពន្ធណាមួយនិងគ្រប់ជាតិពន្ធទាំងអស់មានក្នុងប្រទេសកម្ពុជារួមមាន ជនជាតិខ្មែរនិងឡាវ ក៏ដូចជា សហាគមន៍ជនជាតិខ្មែរនិងឡាវ ក៏ដូចជាសហាគមន៍ ឬក្រុមដែលឆ្លើយតបទៅនឹងនិយមន័យខាងលើ។

## 2. បកស្រាយបញ្ជាក់អំពីទំនាក់ទំនងរវាងបទប្បញ្ញត្តិនៅក្នុងសេចក្តីព្រាងក្រម ENR ស្តីពីការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយចីរភាពជាមួយបទប្បញ្ញត្តិស្តីពីសិទ្ធជាលក្ខណៈប្រពៃណីដែលមាននៅកន្លែងផ្សេងទៀតក្នុងសេចក្តីព្រាងក្រម ENR ក៏ដូចជានៅក្នុងសំណេរច្បាប់ដទៃទៀត។

សេចក្តីព្រាងរបស់ក្រមក្នុងមាត្រា ៣៩៤ ចែងថា "សិទ្ធកាន់កាប់ដីធ្លីសមូហភាពក្រោមការគ្រប់គ្រងរួមគ្នាត្រូវជាសិទ្ធបន្ថែមលើបុព្វសិទ្ធដទៃទៀតដែលសហាគមន៍ជនជាតិដើមភាគតិចអាចទទួលបាន រួមទាំងសិទ្ធដែលមានចែងនៅក្រោមបទប្បញ្ញត្តិច្បាប់និងលិខិតឧបករណ៍ច្បាប់ដទៃទៀត។

មាត្រា ៣៥៨ ចែងថា "អាណត្តិកាន់កាប់និងប្រើប្រាស់ដីរដ្ឋនៃតំបន់គ្រប់គ្រងរួមគ្នាត្រូវជាសិទ្ធបន្ថែមសិទ្ធដទៃទៀតដែលសហាគមន៍ជនជាតិដើមភាគតិចទទួលបានស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន"។

ក្នុងករណីមានជម្លោះរវាងបទប្បញ្ញត្តិមួយណាក្នុងចំណោមបទបទបញ្ញត្តិទាំងពីរខាងលើជាមួយនឹងសិទ្ធសមូហភាពរបស់ជនជាតិដើមភាគតិចដែលត្រូវបានផ្តល់ឱ្យដោយសំណេរច្បាប់ដទៃទៀតយើងពុំឃើញច្បាប់បញ្ជាក់ថាត្រូវយកសំណេរណាមួយជាសំណេរមានឧត្តមានុភាពឡើយ។

បទបញ្ញត្តិក្នុងគន្ថី ៩ ស្តីពីកម្មវិធីប្រភេទដទៃទៀតក្រៅពីការគ្រប់គ្រងរួមគ្នា (CM) ដូចជាប្រព័ន្ធតំបន់ការពារធម្មជាតិនិងច្រករបៀងអភិរក្សជីវចម្រុះគឺពុំបាននិយាយអ្វីស្តីពីទំនាក់ទំនងរវាងសិទ្ធ និងកាតព្វកិច្ចកើតឡើងដោយកម្មវិធីទាំងអស់នេះ និងសិទ្ធរបស់សហាគមន៍ជនជាតិដើមភាគតិចនៅក្រោមសំណេរច្បាប់ដទៃទៀតឡើយ។ នេះនៅពុំទាន់និយាយអំពីសិទ្ធរបស់ម្ចាស់សិទ្ធកាន់កាប់ជាលក្ខណៈប្រពៃណីជាទូទៅនៅឡើយ។ ឧទាហរណ៍ សេចក្តីព្រាងក្រមមាត្រា ៣៩០ ចែងថា ការគ្រប់គ្រងរួមគ្នាអាចត្រូវអនុវត្តចំពោះ "ដីដែលត្រូវបានបម្រុងទុកសម្រាប់ ជនជាតិដើមភាគតិច ឬដីដែលត្រូវបានអភិរក្សជាលក្ខណៈប្រពៃណីដទៃទៀត។ មាត្រា ២៣ នៃច្បាប់ភូមិបាល ចែងថា "ក្នុងពេលរង់ចាំការកំណត់ខាងផ្លូវច្បាប់នូវលក្ខន្តិកៈរបស់សហាគមន៍ក្រុមដែលមានជាក់ស្តែងមកទល់បច្ចុប្បន្ននេះនឹងបន្តគ្រប់គ្រងសហាគមន៍និងចលនវត្ថុរបស់ ខ្លួនតាមប្រពៃណី ហើយត្រូវអនុវត្តតាមបញ្ញត្តិនៃច្បាប់នេះ"។ តើមានអ្វីកើតឡើងនៅពេលមានជម្លោះកើតឡើងដោយចៀសមិនផុតរវាងប្រព័ន្ធគ្រប់គ្រងពីរផ្សេងគ្នានេះ?

ថ្វីបើសេចក្តីព្រាងក្រមនេះពុំបាននិយាយជាក់ច្បាស់ខ្លាំងក្តី ប៉ុន្តែមានការចង្អុលបង្ហាញថាសិទ្ធគ្រប់គ្រងរួមគ្នាគឺត្រូវលុបលើសិទ្ធដទៃទៀត។ មាត្រា ៣៦០ ចែងថា "សិទ្ធប្រើប្រាស់ដីក្នុងក្របខណ្ឌគ្រប់គ្រងរួមគ្នាមិនមែនជាសិទ្ធក្នុងការលក់ ឬផ្ទេរកម្មសិទ្ធទៅលើដីទាំងឡាយដែលត្រូវបានកំណត់ចូលទៅក្នុងតំបន់គ្រប់គ្រងរួមគ្នានោះទេ" (សូមមើលបន្ថែមមាត្រា ៣៥៩) ប៉ុន្តែមានអ្វីកើតឡើងប្រសិនបើតំបន់គ្រប់គ្រងរួមគ្នាដែលពាក់ព័ន្ធទៅ នឹងសិទ្ធគ្រប់គ្រងរួមគ្នានោះក៏ត្រូវបានគ្របដណ្តប់ដោយប័ណ្ណកម្មសិទ្ធ ដីសមូហភាពរបស់ជនជាតិដើមភាគតិច (ICLT) ផងដែរនោះ? នៅក្រោមច្បាប់ភូមិបាល សិទ្ធក្នុងការផ្ទេរដីសមូហភាពរបស់ជនជាតិដើមភាគតិច (ICLT) គឺមានកម្រិតកំណត់។ ម្យ៉ាងវិញទៀតនៅក្នុងមាត្រា ៣៥៩ របស់សេចក្តីព្រាងក្រមនេះចែងថា បន្ទាប់ពី "បានកំណត់ជាតំបន់ការពារក្រោមការគ្រប់គ្រងរួមគ្នា" "ទោះបីមានល័ក្ខខ័ណ្ឌតម្រូវឬការ ចុះបញ្ជីបន្ថែមណាមួយត្រូវធ្វើឡើងក្តី សិទ្ធប្រើប្រាស់ដីក្នុងក្របខណ្ឌគ្រប់គ្រងរួមគ្នាមិនអាចបំពានបានឡើយ"។ ការបង្កើតតំបន់នេះហាក់ជាជំហានចុងក្រោយក្នុងការបង្កើតការគ្រប់គ្រងជាសមូហភាពនៅក្នុងតំបន់មូលដ្ឋានជាក់លាក់ណាមួយ។ ប្រសិនបើដូច្នេះ តើ "ការចុះបញ្ជី ឬល័ក្ខខ័ណ្ឌតម្រូវ" នោះសំដៅលើអ្វី? ប្រសិនបើសំដៅលើ ICLT នោះបានន័យថា សិទ្ធដែលផ្តល់ដោយ ICLT ហាក់ដូចជាមានឋានៈនៅក្រោមល័ក្ខខ័ណ្ឌតម្រូវរបស់ CM។

យើងជឿជាក់ថា ជាការសំខាន់ណាស់ដែលត្រូវបញ្ជាក់ភាពមិនច្បាស់លាស់ទាំងអស់នេះឱ្យបានច្បាស់លាស់ឡើងវិញហើយបញ្ជាក់នៅក្នុងលក្ខណៈមួយដែលធ្វើឱ្យមានប្រសិទ្ធភាពកាន់កាប់ជាលក្ខណៈប្រពៃណីត្រូវមានភាពលុបលើកាតព្វកិច្ចបង្កើតឡើងដោយកាតព្វកិច្ចនៅក្នុងកម្មវិធីដែលមានចែងក្នុងគ ន្តីទី ៩។ ហេតុដូចច្នេះយើងសូមឱ្យបន្ថែមមាត្រាមួយទៀតដូចមាត្រាខាងក្រោមទៅក្នុងគន្តីទី ១ មាតិកាទី ១ ជំពូកទី ២ "គោលការណ៍ទូទៅ" ៖ មាត្រា ២០ គោលការណ៍ដែលចាត់ទុកថា សិទ្ធកាន់កាប់ជាលក្ខណៈប្រពៃណីមានអធិកភាពលើកាតព្វកិច្ចនានាដែលបង្កើតឡើងដោយកម្មវិធីគ្រប់គ្រងដោយធនធានធម្មជាតិប្រកបដោយចីរភាពដែលច្បាប់នេះបានបង្កើតឡើង។

ក្នុងករណីមានភាពខ្វាស់គ្នារវាងកាតព្វកិច្ចដែលបង្កើតឡើងដោយកម្មវិធីគ្រប់គ្រងធនធានធម្មជាតិប្រកបដោយចីរភាពនៅក្នុងច្បាប់ នេះជាមួយ សិទ្ធ ដែលមាន ចែង ក្រោមវិធានបែបប្រពៃណី មិនថាមាន ចែង នៅក្រោមច្បាប់នេះ ឬនៅក្នុងសំណេរច្បាប់ ដទៃទៀតនោះទេ សិទ្ធជាលក្ខ ណៈ ប្រ ពៃ ណី ត្រូវមានឧត្តមានុភាព ។

**3. ត្រូវបញ្ជាក់ឱ្យច្បាស់ថា ការយល់ព្រមដោយសេរី ជាមុន និងផ្អែកលើព័ត៌មានត្រឹមត្រូវ (FPIC) ត្រូវអនុវត្តចំពោះការសម្រេចចិត្តនិងកម្មវិធី ។ ល។ គ្រប់ប្រភេទទាំងអស់ដែលធ្វើឡើងដោយរដ្ឋាភិបាលដែលប៉ះពាល់ដីនិងធនធានធម្មជាតិរបស់សហគមន៍ជនជាតិដើមភាគតិច។**

ចំណុចបន្ថែមដែលត្រូវបានស្នើឡើងក្នុងអក្សរពណ៌ខៀវ និងចំណុចដែលត្រូវលុបចេញគឺក្នុងចំណុចគូសចោលពណ៌ក្រហម

មានបទប្បញ្ញត្តិដ៏រឹងមាំជាច្រើនស្តីពី FPIC នៅក្នុងសេចក្តីព្រាងក្រម ENR ប៉ុន្តែនៅពុំមានភាពច្បាស់លាស់ទាំងស្រុងថាតើបទប្បញ្ញត្តិទាំងអស់នោះគ្រប់ដណ្តប់លើការសម្រេចចិត្តទាំងអស់របស់រដ្ឋាភិបាលដែលអាចប៉ះពាល់ដល់ដីនិងធនធានធម្មជាតិរបស់ ICs ឬយ៉ាងណានោះឡើយ។ ឧទាហរណ៍ FPIC ត្រូវអនុវត្តចំពោះការគ្រប់គ្រងប្រព័ន្ធតំបន់ការពារ (PAS) (មាត្រា ២៩១) ប៉ុន្តែពុំមានការបញ្ជាក់អំពី FPIC ទាក់ទងទៅ នឹងការ បង្កើត PAS ច្រករបៀង អភិរក្សជីវសាស្ត្រចម្រុះ (BDCCs) ឬគម្រោង ការគ្រប់គ្រងរួមគ្នានោះឡើយ។ មាត្រា ១៨ ចែងថា FPIC ត្រូវអនុវត្តចំពោះ "គម្រោងដែលត្រូវបានស្នើឡើងទាំងអស់"។ នៅក្នុងសេចក្តីព្រាងទី ១០ នៃក្រមនេះ កំណត់និយមន័យ "គម្រោង" ថាជា "សកម្មភាព កម្មវិធី អាជីវកម្ម សេវាកម្ម ឬការអនុវត្តដទៃទៀតទាំងអស់របស់វិស័យសាធារណៈ ឬឯកជន ដោយក្នុងនោះការអនុវត្តទាមទារឱ្យមានការអនុញ្ញាត ឬការអនុម័ត ឬស្ថិតក្រោមនិយ័តកម្មរបស់រដ្ឋាភិបាល"។ និយមន័យក្នុងសទ្ទានុក្រមនេះហាក់គ្របដណ្តប់លើទិដ្ឋភាពដូចជា ការបង្កើត PAS, BDCC ឬគម្រោងគ្រប់គ្រងរួមគ្នាប៉ុន្តែជាក់ស្តែងតើពិតជាមានភាពគ្របដណ្តប់ ឬយ៉ាងណា? ទោះយ៉ាងណាក្តី បទប្បញ្ញត្តិ FPIC ពុំត្រូវបានពង្រីកដើម្បីគ្របដណ្តប់ទៅលើដីដែលកាន់កាប់ជាលក្ខណៈប្រពៃណីនិងធនធានធម្មជាតិជាទូទៅនោះឡើយ។ ហេតុដូច្នេះយើងស្នើឱ្យធ្វើវិសោធនកម្មលើមាត្រា ១៨ ដូចខាងក្រោម។

> មាត្រា ១៨៖ គោលការណ៍នៃការយល់ព្រមជាមុន ដោយសេរី និងបន្ទាប់ពីទទួលបានព័ត៌មានគ្រប់ជ្រុងជ្រោយសម្រាប់សហគមន៍ ~~ជនជាតិដើមភាគតិច~~ ជាម្ចាស់សិទ្ធកាន់កាប់ជាលក្ខណៈប្រពៃណី
>
> រាល់សកម្មភាព គម្រោង ឬកម្មវិធី ឬសកម្មភាពដែលបានស្នើឡើងដែលអាចប៉ះពាល់ដល់សិទ្ធកាន់កាប់ជាលក្ខណៈប្រពៃណីជាពិសេសការអភិវឌ្ឍការប្រើប្រាស់ដី ឬការដកហូតធនធានធម្មជាតិ ដោយវិស័យឯកជន ឬដោយរដ្ឋាភិបាលរួមទាំងការបង្កើតតំបន់ការពារថ្មីត្រូវមានការយល់ព្រមជាមុន ដោយសេរី ក្រោមមូលដ្ឋានព័ត៌មានគ្រប់ជ្រុងជ្រោយពីសហគមន៍។

**4. ចែងបទប្បញ្ញត្តិស្តីពីសកម្មភាពបែបពាណិជ្ជកម្មនៅក្នុងតំបន់ការពារធម្មជាតឱ្យកាន់តែមានលក្ខណៈជាក់ច្បាស់សម្រាប់សហគមន៍មូលដ្ឋាន។**

សេចក្តីព្រាងក្រមមានបទប្បញ្ញត្តិជាច្រើនដែលអនុញ្ញាតឱ្យមានសកម្មភាពបែបពាណិជ្ជកម្មនៅខាងក្នុងតំបន់ការប្រើប្រាស់ដោយចីរភាពនិងតំបន់សហគមន៍នៅក្នុងតំបន់ការពារធម្មជាតិ។ ចំណុចទាំងនេះអនុញ្ញាតឱ្យមានឱកាសសម្រាប់សហគមន៍មូលដ្ឋានក្នុងការកែលម្អជីវភាពរស់នៅរបស់ខ្លួន ហើយស្របពេលជាមួយគ្នានោះក៏ជួយធានាឱ្យមានការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយចីរភាពផងដែរ។ ប៉ុន្តែនៅពុំទាន់មានភាពច្បាស់លាស់ថាតើសកម្មភាពបែបពាណិជ្ជកម្មទាំងអស់នេះអាចកើតមានបាននៅក្នុងតំបន់ការពារធម្មជាតិសហគមន៍ (CPAs) ឬយ៉ាងណាឡើយ។ ដោយហេតុនេះ យើងខ្ញុំសុំស្នើឱ្យមានចំណុចបន្ថែមក្នុងពណ៌ខៀវដូចខាងក្រោមសម្រាប់មាត្រា ៣១៥ ដើម្បីធ្វើឱ្យបទប្បញ្ញត្តិនេះកាន់តែមានភាពជាក់ច្បាស់ថែមទៀត។

## 5. ការកែសម្រួលឡើងវិញដែលត្រូវបានស្នើឡើងទៅលើមាត្រាផ្សេងៗដទៃទៀត។

ចំណុចបន្ថែមដែលត្រូវបានស្នើឡើងក្នុងអក្សរពណ៌ខៀវ និងចំណុចដែលត្រូវលុបចេញគឺក្នុងចំណុចគូសចោលពណ៌ក្រហម

មាត្រា ២៨៥៖ ការបង្កើតតំបន់ការពារធម្មជាតិនិងអចលនទ្រព្យរបស់ប្រជាពលរដ្ឋមូលដ្ឋាន និងជនជាតិដើមភាគតិច។

ក្រសួង ឬស្ថាប័នទទួលបន្ទុកបរិស្ថាននិងធនធានធម្មជាតិអាចបង្កើតសមាសភាគនៃប្រព័ន្ធតំបន់ការពារធម្មជាតិសម្រាប់តំបន់ណាដែលមានសារៈសំខាន់ជារួម ឬតំបន់ដែលមានសារៈប្រយោជន៍សំខាន់ដល់សហគមន៍ មូលដ្ឋាន ឬជនជាតិដើមភាគតិចតាមការស្នើសុំរបស់សហគមន៍មូលដ្ឋាន ឬជនជាតិដើមភាគតិច។

មាត្រា ៣១១ (កថាខណ្ឌទី ៣)

ការកំណត់តំបន់គ្រប់គ្រងត្រូវមានការចូលរួមពិគ្រោះយោបល់ជាមួយ អាជ្ញាធរមូលដ្ឋានសហគមន៍មូលដ្ឋាននៅក្នុងនិងក្បែរតំបន់ការពារធម្មជាតិ និងដៃគូពាក់ព័ន្ធដែលមានបទពិសោធន៍ស្រាវជ្រាវ ការពារ អភិរក្ស និងគ្រប់គ្រងធនធានធម្មជាតិ និងអ្នកពាក់ព័ន្ធផ្សេងទៀតដូចមានចែងក្នុងគន្លឹទី ១ មាតិកាទី ២ និងមាតិកាទី ៣ នៃក្រមនេះ។ ការកំណត់តំបន់គ្រប់គ្រងត្រូវទទួលបានការយល់ព្រមដោយសេរី ជាមុន និងផ្អែកលើព័ត៌មានត្រឹមត្រូវពីសហគមន៍ ជាម្ចាស់សិទ្ធកាន់កាប់ជាលក្ខណៈប្រពៃណីនៅក្នុងការពារធម្មជាតិ។

មាត្រា ៣១១ (ចំណុចទី ៣ និងទី ៤)

៣. តំបន់ប្រើប្រាស់ដោយចីរភាព៖ តំបន់គ្រប់គ្រងដែលមានសក្តានុពលសេដ្ឋកិច្ចនិងមានតម្លៃសម្រាប់ការអភិរក្ស និងប្រព័ន្ធអេកូឡូស៊ីដែលមានសក្តានុពលក្នុងការចូលរួមចំណែកលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាសហគមន៍មូលដ្ឋាននិងជនជាតិដើមភាគតិចប្រកបដោយចីរភាព។ ដីធ្លីនិងធនធានធម្មជាតិទាំងឡាយណាដែលត្រូវបានគ្របដណ្តប់ដោយការកំណត់តំបន់គ្រប់គ្រងនេះដែលរួមតំបន់គ្រប់គ្រងនេះដែលរួមមានដីធ្លី និងធនធានធម្មជាតិជាលក្ខណៈប្រពៃណីរបស់សហគមន៍មូលដ្ឋាននិងប្រជាជនជាតិដើមភាគតិចដែលពុំមានសិទ្ធទទួលបានកម្មសិទ្ធដីអាចក្លាយជាក្លាយជាកម្មវត្ថុនៃការចុះបញ្ជីដីធ្លី និងការធ្វើប័ណ្ណកម្មសិទ្ធដីធ្លីក្នុងលក្ខណៈជាប័ណ្ណកម្មសិទ្ធសហគមន៍គ្រប់គ្រងរួមគ្នា។ ដីនិងធនធានធម្មជាតិទាំងអស់នេះអាចត្រូវបានគ្របដណ្តប់ដោយប័ណ្ណកម្មសិទ្ធរបស់សហគមន៍គ្រប់គ្រងរួមគ្នារួមមានជាអាទិ៍ដូចជា ប្រភពទឹកតំបន់ វាលស្មៅ សម្រាប់ចិញ្ចឹមសត្វពាហនៈ តំបន់ជលផល និងព្រៃឈើព្រមទាំងតំបន់ដទៃទៀត។

៤. តំបន់សហគមន៍៖ តំបន់គ្រប់គ្រងសម្រាប់អភិវឌ្ឍសេដ្ឋកិច្ច និងសង្គមនៃសហគមន៍មូលដ្ឋាន និងជនជាតិដើមភាគតិចដែលមានសកម្មភាពកំពុងប្រើប្រាស់និងមានស្រាប់រួមមាន ដីនិងធនធានធម្មជាតិដែលត្រូវបានប្រើប្រាស់ជាលក្ខណៈប្រពៃណីរបស់ពួកគេដោយក្នុងនោះអាចមានជាអាទិ៍ដូចជា ដីលំនៅឋាន វាលស្រែ ចំការ វាលស្មូនដំណាំ ឬចម្ការវិលជុំ ដីកប់សព ប្រភពទឹក កន្លែងនេសាទ តំបន់វាលស្មៅ សម្រាប់ចិញ្ចឹមសត្វពាហនៈ ព្រៃឈើ រួមទាំងព្រៃសក្តិសិទ្ធ និងដីបម្រុងទុក ព្រមទាំងតំបន់ដទៃទៀត។ ការប្រើប្រាស់មួយចំនួននៃការប្រើប្រាស់ខាងលើអាចត្រូវបានចាត់ទុកថាជាការប្រើប្រាស់ផ្តាច់មុខនិងអាចផ្តល់ប័ណ្ណកម្មសិទ្ធដល់សហគមន៍ជនជាតិឬប័ណ្ណកម្មសិទ្ធសមូហភាពក្រោមច្បាប់ភូមិបាលឆ្នាំ ២០០១ អនុក្រឹត្យលេខ ៨៣ (២០០៩) ស្តីពីនីតិវិធីសម្រាប់ការចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិច ឬច្បាប់ស្តីពីតំបន់ការពារធម្មជាតិឆ្នាំ ២០០៨ ក្នុងមាត្រា ១១ ៖ ដីលំនៅឋាន វាលស្រែ ចំការ វាលស្មូនដំណាំ ឬចម្ការវិលជុំ ដីកប់សព ប្រភពទឹក កន្លែងនេសាទ តំបន់វាលស្មៅសម្រាប់ចិញ្ចឹមសត្វពាហនៈ ព្រៃឈើ រួមទាំងព្រៃសក្តិសិទ្ធ និងដីបម្រុងទុក។ ការប្រើប្រាស់មួយចំនួននៃការប្រើប្រាស់ខាងលើអាចជាកម្មវត្ថុនៃប័ណ្ណកម្មសិទ្ធសហគមន៍គ្រប់គ្រងរួមគ្នាតែប៉ុណ្ណោះ ដែលផ្តល់សិទ្ធអាស្រ័យផល អចិន្ត្រៃយ៍ដល់សហគមន៍ជនជាតិខ្មែរនិងសហគមន៍ជនជាតិដើមភាគតិច៖ ប្រភពទឹក តំបន់វាលស្មៅសម្រាប់ចិញ្ចឹមសត្វពាហនៈ តំបន់នេសាទ និងព្រៃឈើ។”

មាត្រា ៣១៩៖

ក្រសួង ឬស្ថាប័នទទួលបន្ទុកបរិស្ថាននិងធនធានធម្មជាតិ រដ្ឋបាលថ្នាក់ក្រោមជាតិ និងអង្គភាពពាក់ព័ន្ធដែលមានសមត្ថកិច្ចក្នុងការគ្រប់គ្រងនៅក្នុងផ្នែកណាមួយនៃប្រព័ន្ធតំបន់ការពារធម្មជាតិអាចកំណត់ផ្នែកជាក់លាក់ នៃតំបន់ប្រើប្រាស់ដោយចីរភាព ~~ឬតំបន់សហគមន៍នោះ~~ ដែលមានសក្តានុពលផ្នែកសេដ្ឋកិច្ច និងតម្លៃប្រព័ន្ធអេកូឡូស៊ី និងតម្លៃនៃការអភិរក្សទាបធ្វើជាធ្វើជាតំបន់សម្រាប់សកម្មភាពពាណិជ្ជកម្ម។

មាត្រា ៣៤០៖
មាតិកានេះមានវិសាលភាពអនុវត្តចំពោះតំបន់ទាំងឡាយដែលអាចទទួលបានការអនុវត្តតាមការគ្រប់គ្រងរួមគ្នា។ ប្រព័ន្ធតំបន់ការពារធម្មជាតិ សហគមន៍តំបន់ការពារធម្មជាតិ សមាគមព្រៃឈើ សហគមន៍នេសាទ និងសហគមន៍នានាដែលបានដាក់ពាក្យស្នើសុំការកំណត់ជាសហគមន៍ព្រៃឈើពីមុនរួចហើយ ឬដែលបានត្រៀមឯកសារបំណង នឹងដាក់ពាក្យស្នើរសុំការកំណត់ជាសហគមន៍ព្រៃឈើដីបម្រុងទុករបស់ជនជាតិដើមភាគតិចឬ ជាលក្ខណៈប្រពៃណីដទៃទៀតលើដីសាធារណៈរបស់រដ្ឋដែលមានតម្លៃអភិរក្សនិងតម្លៃប្រព័ន្ធអេកូឡូស៊ីត្រូវមានសិទ្ធទទួលបានការគ្រប់គ្រងស្របតាមគោលការណ៍នៃការគ្រប់គ្រងរួមគ្នាដូចមានចែងក្នុងមាតិកានេះ។

សម្គាល់៖ អនុក្រឹត្យលេខ ៨៣ (២០០៩) ស្តីពីនីតិវិធីចុះបញ្ជីដីសហគមន៍ជនជាតិដើម ភាគតិចទទួលស្គាល់ដីបម្រុងទុករបស់ជនជាតិដើមភាគតិចថាជា ដី មាន លក្ខណៈសម្បត្តិគ្រប់គ្រាន់ ដើម្បី ទទួលបានប័ណ្ណកាន់កាប់ដីសមូលហភាព។ ហេតុនេះ ដីបម្រុងទុកទាំងនេះមិនគួរស្ថិតក្នុងវិសាលភាពនៃគម្រោងការគ្រប់គ្រងរួមគ្នាទេ។

### 6. បន្ថែមមាត្រាការពារអន្តរកាលទាក់ទងនឹងការគ្រប់គ្រងរួមគ្នា (CM)។

ការបង្កើតតំបន់គ្រប់គ្រងរួមគ្នាប្រាកដជាត្រូវការរយៈពេលវែងមិនខុសពីដំណើរការនៃការចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិច (ICLR) នោះទេ។ នីតិវិធី ICLR រួមមាន ប្រកាសរួមស្តីពីការការពារអន្តរកាលលើដីសហគមន៍ជនជាតិដើមភាគតិច។ ដូចគ្នានេះដែរយើងខ្ញុំសុំស្នើឱ្យ បន្ថែមមាត្រាការពារអន្តរកាលមួយសម្រាប់ដីដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដើម្បីអាចទទួលបានការគ្រប់គ្រងរួមគ្នា៖

មាត្រា XX កិច្ចការពារអន្តរកាល
ជនទទួលបន្ទុកគ្រប់គ្រងតំបន់ណាមួយដែលមានសិទ្ធទទួលបានការគ្រប់គ្រងរួមគ្នាគឺមានសិទ្ធអាចដាក់ពាក្យទៅកាន់ក្រសួង ឬស្ថាប័នទទួលបន្ទុកផ្នែកបរិស្ថាននិងធនធានធម្មជាតិដើម្បីសុំការការពារអន្តរកាលសម្រាប់តំបន់នោះ។ ការដាក់ពាក្យសុំអាចធ្វើឡើងនៅពេលណាក៏បានរួមទាំងនៅមុនការផ្តួចផ្តើមដំណើរការបង្កើតការគ្រប់គ្រងរួមគ្នា។ ការដាក់ពាក្យសុំការការពារអន្តរកាលត្រូវមានលក្ខណៈសាមញ្ញនិងគួរមានផែនទីអមមកជាមួយដែលបង្ហាញអំពីតំបន់ដែលត្រូវបានស្នើសុំសម្រាប់ការការពារអន្តរកាល។ បច្ចេកទេសដើម្បីធ្វើផែនទីត្រូវមានលក្ខណៈប្រហាក់ប្រហែលទៅនឹងបច្ចេកទេសដែលត្រូវបានប្រើប្រាស់ដើម្បីធ្វើផែនទីបឋមគួរមានលក្ខណៈប្រហាក់ប្រហែលគ្នានឹងផែនទីបឋមសម្រាប់ ការដាក់ពាក្យសុំចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិច។ ការសម្រេចចិត្តលើការដាក់ពាក្យសុំការការពារអន្តរកាលនេះត្រូវតែធ្វើឡើងឱ្យបានឆាប់រហ័សនិងមានពេលវេលាកំណត់ជាកលាក់។ ផលដែលចេញពីការអនុវត្តការការពារអន្តរកាលនេះគួរតែធ្វើយ៉ាងណាហាមមិនឱ្យមានការអភិវឌ្ឍផ្នែកពាណិជ្ជកម្មណាមួយត្រូវបានអនុញ្ញាតដោយណាមួយត្រូវបានអនុញ្ញាតដោយមន្ត្រីរដ្ឋាភិបាលឬទីភ្នាក់ងារណាមួយហើយពុំមានសកម្មភាពពាណិជ្ជកម្មប្រភេទណាមួយអាចត្រូវបានអនុញ្ញាតក្រៅពីអាជីវកម្មខ្នាតតូចជាលក្ខណៈគ្រួសារ។គួរមានការប្រកាសមួយចេញដោយរដ្ឋមន្ត្រីរបស់ក្រសួងឬស្ថាប័នទទួលបន្ទុកផ្នែកបរិស្ថាននិងធនធានធម្មជាតិដើម្បីអធិប្បាយលម្អិតអំពីដំណើរការនៃការការពារអន្តរកាល។

### 7. ផ្តល់សិទ្ធឱ្យបុគ្គលនិងអង្គភាពដើម្បីជួយដល់សហគមន៍ឱ្យយល់អំពីក្រម ENR។

ក្រម ENR ជាក្រមដែលវែងនិងមានភាពស្មុគស្មាញ និងពិបាកសម្រាប់សហគមន៍អាចយល់បាន។ យើងខ្ញុំសុំស្នើឱ្យបន្ថែមចំណុចប្រហាក់ប្រហែលដូចខាងក្រោមទៅក្នុងគន្ថីទី ១ មាតិកាទី ១ ជំពូកទី ២៖ គោលការណ៍ទូទៅ៖

មាត្រា XX សិទ្ធទទួលបានជំនួយ
អង្គការនិងបុគ្គលទាំងឡាយដែលមានសមត្ថភាពពាក់ព័ន្ធអាចជួបនិងជួយដល់សហគមន៍ដែលរងផលប៉ះពាល់ដោយក្រមនេះដើម្បីឱ្យពួកគាត់អាចយល់និងអនុវត្តសិទ្ធរបស់ខ្លួននៅក្រោមក្រមនេះ។

ប្រសិនបើក្រមបរិស្ថាននិងធនធានធម្មជាតិដែលត្រូវបានអនុម័តជាទូទៅមានលក្ខណៈស្រដៀងគ្នាទៅទៅនឹងសេចក្តីព្រាងក្រមដែលត្រូវបានយកមកពិនិត្យសម្រាប់កំណត់សម្គាល់នេះវា នឹងមានផលជះធំធេងយ៉ាងខ្លាំងទៅលើសិទ្ធកាន់កាប់ដីធ្លីនិងធនធានធម្មជាតិរបស់ជនដែលមានសិទ្ធកាន់កាប់ជាលក្ខណៈប្រពៃណី។ ដោយសារតែយើងមានការព្រួយបារម្ភអំពីសិទ្ធបែបនេះការផ្តល់មតិយោបល់នៅក្នុងឯកសារ នេះត្រូវបានចែករំលែកក្នុងគោលបំណងបង្កឱ្យមានផលប៉ះពាល់ជាវិជ្ជមានសម្រាប់កសិករខ្នាតតូចនិងសហគមន៍ជនជាតិដើមភាគតិចក្នុងប្រទេសកម្ពុជា។ ក្រមនេះគឺជាមូលដ្ឋានសម្រាប់ផ្តល់ការបញ្ជាក់ស្ថាពរចំពោះស្ថានភាពស្របច្បាប់នៃសិទ្ធកាន់កាប់ជាលក្ខណៈប្រពៃណីដើម្បីចែងបញ្ជាក់ដោយផ្ទាល់ថាតើមានអំណាចតាមផ្លូវច្បាប់ណាខ្លះដែលភ្ជាប់ទៅនឹងសិទ្ធកាន់កាប់ជាលក្ខណៈប្រពៃណីទាំងនេះព្រមទាំងបញ្ជាក់ឱ្យបានច្បាស់លាស់ថាតើនរណាខ្លះមានសិទ្ធបែបនេះ ។ យើងសង្ឃឹមថា នៅក្នុងឯកសារនេះយើងបានផ្តល់មតិយោបល់ដែលអាចជួយឱ្យក្រមនេះសម្រេចបាននូវលទ្ធផលទាំងនេះ៕

ឯកសារពិភាក្សាត្រូវបានរៀបចំឡើងដោយមានការពិគ្រោះយោបល់ជាមួយ Christian Castellanet and Ngo Sothath (MRLG), Alistair Mould, Teng Rithiny, and Chea Phalla (WCS), Hou Kalyan (RECOFTC), Poch Sophorn (IMG), Florian Rock និង Antoine Deligne.

ដៃគូសហការ៖

THE CENTER FOR PEOPLE AND FORESTS

វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា The NGO Forum on Cambodia

IMG

សម្រង់ឯកសារយោងទាំងស្រុង៖ Cooper, G. (2019) ការពិនិត្យឡើងវិញ មតិយោបល់ និងអនុសាសន៍លើសេចក្តីព្រាងក្រមបរិស្ថាន និងធនធានធម្មជាតិ (កំណែទី ១១) របស់ប្រទេសកម្ពុជា, ឯកសារពិភាក្សា ទី៩, វៀងចន្ទ៖ អភិបាលកិច្ចដីធ្លីតំបន់ទន្លេមេគង្គ។

CC BY NC SA

កិច្ចការនេះផ្តល់អាជ្ញាប័ណ្ណនៅក្រោមគោលការណ៍ **Creative Commons Attribution-NonCommercial-ShareAlike 4.0 International (CC BY-NC-SA 4.0)**

គម្រោងអភិបាលកិច្ចដីធ្លីតំបន់ទន្លេមេគង្គ (MRLG) មានគោលបំណងលើកកម្ពស់សន្តិសុខនៃសិទ្ធកាន់កាប់ដីធ្លីរបស់កសិករខ្នាតតូចនៅក្នុងតំបន់ទន្លេមេគង្គ តាមរយៈការចូលរួមចំណែកក្នុងការតាក់តែង និងការអនុវត្តគោលនយោបាយដីធ្លីដែលសមស្រប។ គម្រោងនេះឆ្លើយតបទៅនឹងអាទិភាពថ្នាក់ជាតិ ពាក់ព័ន្ធនឹងការកាត់បន្ថយភាពក្រីក្រ ការបង្កើនកិច្ចអភិវឌ្ឍន៍ សេដ្ឋកិច្ច និងការគាំទ្រដល់កសិករខ្នាតតូចសេដ្ឋកិច្ច និងការគាំទ្រដល់កសិករខ្នាតតូច ដើម្បីពួកគេអាចមានសន្តិសុខនិងអាចធ្វើសេចក្តីសម្រេចចិត្តត្រឹមត្រូវស្តីពីការប្រើប្រាស់និងការគ្រប់គ្រងដីធ្លី។ MRLG ប្រតិបត្តិការនៅក្នុងប្រទេសកម្ពុជា ឡាវ មីយ៉ាន់ម៉ា និងវៀតណាម ចាប់តាំងពីខែមេសា ឆ្នាំ ២០១៤ មកម្លេះ។

សម្រាប់ព័ត៌មានបន្ថែមអំពីគម្រោង MRLG សូមស្វែងរកនៅលើគេហទំព័រ www.mrlg.org

គម្រោងអភិបាលកិច្ចដីធ្លីតំបន់ទន្លេងមេគង្គ (MRLG) គឺជាគម្រោងមួយរបស់រដ្ឋាភិបាលប្រទេសស្វីស តាមរយៈទីភ្នាក់ងារស្វីសសម្រាប់ការអភិវឌ្ឍនិងកិច្ចសហប្រតិបត្តិការ (SDC) ដោយមានហិរញ្ញប្បទានបដិភាគពីក្រសួងសហព័ន្ធអាល្លឺម៉ង់សម្រាប់កិច្ចសហប្រតិបត្តិ ការសេដ្ឋកិច្ចនិងការអភិវឌ្ឍ (BMZ) និងរដ្ឋាភិបាលលុចហ្សំប៊ួរ។

គម្រោង MRLG អនុវត្តដោយក្រុមហ៊ុន សមធម៌ដីធ្លីអន្តរជាតិ (Land Equity International) ហៅកាត់ថា LEI សហការណ៍ជាមួយអង្គការ GRET អ្នកវិជ្ជាជីវៈដើម្បីការអភិវឌ្ឍដោយយុត្តិធម៌ និងគាំទ្រដោយអង្គការ GIZ។

គម្រោងអភិបាលកិច្ចដីធ្លីតំបន់ទន្លេមេគង្គ
បន្ទប់លេខ ១១ ផ្ទះលេខ ២៦២ Ban Saphanthong Kang, ស្រុក Sisattanak ក្រុងវៀងចន្ទ
សាធារណរដ្ឋប្រជាមានិតឡាវ
ប្រអប់សំបុត្រ ២៩៧៣ Vientiane Lao PDR 01000

សេចក្តីប្រកាសមិនទទួលខុសត្រូវ៖
ទស្សនៈមតិយោបល់និងការបកស្រាយនៅក្នុងឯកសារបោះពុម្ពផ្សាយនេះគឺជាការទទួលខុសត្រូវរបស់អ្នកនិពន្ធនិងអ្នកផ្តល់វិភាគទាន។ ទស្សនៈ មិតយោបល់ និងការបកស្រាយទាំងនេះមិនឆ្លុះបញ្ចាំងពីទស្សនៈឬគោលគំហរផ្លូវការឬមិនផ្លូវការរបស់ SDC, BMZ និង លុចហ្សំប៊ួរ ឡើយ។

ឧបត្ថម្ភមូលនិធិដោយ៖

Schweizerische Eidgenossenschaft
Confédération suisse
Confederazione Svizzera
Confederaziun svizra
Swiss Agency for Development and Cooperation SDC

german cooperation
DEUTSCHE ZUSAMMENARBEIT

GRAND DUCHY OF LUXEMBOURG

អនុវត្តដោយ៖

LAND equity

GRET
Professionals for Fair Development

គាំទ្រដោយ៖

giz